GC LiFE

# គម្រោងសេចក្តីស្រលាញ់
# យូរអង្វែង



## តើអ្វីទៅជាគម្រោងសេចក្តីស្រលាញ់យូរអង្វែង?

គម្រោងសេចក្តីស្រលាញ់យូរអង្វែង គឺជាគម្រោងធានារ៉ាប់រងមួយដែលនឹងនៅការពារអ្នក និងមនុស្សជាទីស្រលាញ់របស់អ្នករហូតដល់ចាស់សក់ស្កូវ។ គម្រោងនេះផ្តល់នូវការការពារយ៉ាងពេញលេញជាមួយនឹងទឹកប្រាក់ផ្តល់ត្រឡប់រហូតដល់ ២៥០% នៃទឹកប្រាក់ត្រូវបានធានា។

## តើអ្នកណាសាកសមនឹងគម្រោងមួយនេះ?

បុគ្គលដែលមានអាយុចន្លោះពី18 - 55ឆ្នាំ។

## ហេតុអ្វីបានជាចាំបាច់ជ្រើសរើសគម្រោងសេចក្តីស្រលាញ់យូរអង្វែង?

គម្រោងសេចក្តីស្រលាញ់យូរអង្វែង ផ្តល់នូវការការពារ និងអត្ថប្រយោជន៍ច្រើនជាងគម្រោងធានារ៉ាប់រងអាយុជីវិតទូទៅ។ គម្រោងនេះមិនត្រឹមតែផ្តល់នូវការការពារ លើមរណភាព និងពិការភាពជាអចិន្ត្រៃយ៍តែប៉ុណ្ណោះទេ ថែមទាំងផ្តល់នូវការការពារលើជំងឺធ្ងន់ធ្ងរ និងការលើកលែងបុព្វលាភនៅពេលកើតជំងឺធ្ងន់ធ្ងរផងដែរ។ លើសពីនេះទៅទៀត នៅពេលអ្នកចាស់ទៅ អ្នកនឹងអាចទទួលបានប្រាក់ជាច្រើន ដោយពុំចាំបាច់ព្រួយបារម្ភពីជីវិតក្រោយពេលចូលនិវត្តន៍ឡើយ។ អ្វីដែលសំខាន់បំផុតនោះគឺបុព្វលាភរបស់គម្រោងសេចក្តីស្រលាញ់យូរអង្វែងនឹងនៅថេរជារៀងរហូត ហើយនឹងមិនមានការកើនឡើងទៅតាមអាយុរបស់អ្នកដូចទៅនឹងផលិតផលធានារ៉ាប់រងមួយចំនួនឡើយ។

## កម្មវត្ថុនៃការធានារ៉ាប់រង

អាយុជីវិតនៃអ្នកត្រូវបានធានារ៉ាប់រង។

## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុអ្នកត្រូវបានធានារ៉ាប់រង | 18 – 55ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | រហូតដល់អ្នកត្រូវបានធានារ៉ាប់រងអាយុ 80ឆ្នាំ |
| រយៈពេលបង់បុព្វលាភ | 5, 10, 15, 20, 25, 30ឆ្នាំ |
| ទឹកប្រាក់ត្រូវបានធានា | ចាប់ពី $10,000ឡើង |

## លក្ខខណ្ឌនៃការបង់បុព្វលាភ

| | |
|---|---|
| វិធីសាស្រ្តបង់បុព្វលាភ | ប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំត្រីមាស ប្រចាំខែ |
| មធ្យោបាយបង់បុព្វលាភ | ការផ្ទេរប្រាក់តាម App ឬគណនីធនាគារ សាច់ប្រាក់ មូលប្បទានបត្រ |
| ការបំពាន | បន្ទាប់ពីការបង់បុព្វលាភធានារ៉ាប់រងលើកទី ១ (មួយ) ការខកខានក្នុងការបង់បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់នៅកាលបរិច្ឆេទដល់កាលកំណត់បង់នឹងត្រូវបានចាត់ទុកជាការបំពានលក្ខខណ្ឌបង់បុព្វលាភធានារ៉ាប់រង។ ប្រសិនបើបុព្វលាភធានារ៉ាប់រងនៅតែមិនទាន់បានបង់បន្ទាប់ពីរយៈពេលអនុគ្រោះ (30ថ្ងៃ) ដល់កាលកំណត់ បណ្ណសន្យារ៉ាប់រងនឹងត្រូវផ្អាកសុពលភាព គិតចាប់ពីថ្ងៃបន្ទាប់នៃថ្ងៃផុតកំណត់នៃរយៈពេលអនុគ្រោះ ហើយបណ្ណសន្យារ៉ាប់រងនេះនឹងមិនមានសុពលភាពក្នុងអំឡុងពេលនៃការផ្អាកសុពលភាពនេះឡើយ។ |

## វិសាលភាពនៃការធានារ៉ាប់រង

ផលិតផលនេះផ្តល់ការការពារលើមរណភាព ពិការភាពជាអចិន្ត្រៃយ៍ ជំងឺធ្ងន់ធ្ងរ និងការលើកលែងបុព្វលាភករណីរកឃើញជំងឺធ្ងន់ធ្ងរ ក្នុងអំឡុងពេលដែលបណ្ណសន្យារ៉ាប់រងកំពុងមានសុពលភាព។
អត្ថប្រយោជន៍នៅរស់រានមានជីវិតនឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានានៅរស់រានមានជីវិតរហូតដល់អាយុ 60ឆ្នាំ។
អត្ថប្រយោជន៍នៅពេលដល់កាលកំណត់នឹងត្រូវផ្តល់ជូន ក្នុងករណីអ្នកត្រូវបានធានានៅរស់រានមានជីវិតរហូតដល់ពេលដែលកិច្ចសន្យាដល់កាលកំណត់។

## អត្ថប្រយោជន៍ធានារ៉ាប់រង

| អត្ថប្រយោជន៍នៅរស់រានមានជីវិត | អត្ថប្រយោជន៍នៅពេលដល់កាលកំណត់ | មរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺ | មរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ |
|---|---|---|---|
| ទទួលបាន 150%នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើអ្នកត្រូវបានធានានៅរស់រានមានជីវិតរហូតដល់អាយុ 60ឆ្នាំ | ទទួលបាន 100% នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើអ្នកត្រូវបានធានានៅរស់រានមានជីវិតរហូតដល់ពេលដែលកិច្ចសន្យាដល់កាលកំណត់ | • ទទួលបាន 100%នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើកើតហេតុក្នុងចន្លោះពេលដែលកិច្ចសន្យាមិនទាន់គ្រប់ 2ឆ្នាំ<br>• ទទួលបាន 150%នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើកើតហេតុក្នុងចន្លោះពេលដែលកិច្ចសន្យាគ្រប់ 2ឆ្នាំ រហូតដល់អ្នកត្រូវបានធានាមានអាយុ 60ឆ្នាំ<br>• ទទួលបាន 100%នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើកើតហេតុក្រោយពេលអ្នកត្រូវបានធានាមានអាយុ 60ឆ្នាំ | • ទទួលបាន 300%នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើកើតហេតុមុនពេលអ្នកត្រូវបានធានាមានអាយុ 60ឆ្នាំ<br>• ទទួលបាន 100%នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើកើតហេតុក្រោយពេលអ្នកត្រូវបានធានាមានអាយុ 60ឆ្នាំ |

## ការផ្តល់ជូននូវអត្ថប្រយោជន៍បន្ថែមដោយឥតគិតថ្លៃ

គិតចាប់ពីថ្ងៃដែលកិច្ចសន្យាគ្រប់ 2ឆ្នាំ រហូតដល់អ្នកត្រូវបានធានាមានអាយុ 60ឆ្នាំ ប្រសិនបើបុព្វលាភក្រោមកិច្ចសន្យាត្រូវបានបង់គ្រប់ចំនួនសម្រាប់រយៈពេល 2ឆ្នាំ អត្ថប្រយោជន៍បន្ថែមដូចខាងក្រោមនឹងត្រូវផ្តល់ជូន៖

| ជំងឺធ្ងន់ធ្ងរ 4ប្រភេទ (ប្រភេទ A) | ជំងឺធ្ងន់ធ្ងរ 34ប្រភេទ (ប្រភេទ B) | ការលើកលែងបុព្វលាភ |
|---|---|---|
| ទទួលបាន 100%នៃទឹកប្រាក់ត្រូវបានធានាសម្រាប់ព្យាបាលជំងឺធ្ងន់ធ្ងរ ប្រសិនបើធ្វើរោគវិនិច្ឆ័យលើកដំបូង រកឃើញជំងឺមហារីកសុដន់ មហារីកស្បូន មហារីកមាត់ស្បូន ឬ មហារីកក្រពេញប្រូស្តាត | ទទួលបានសំណងមួយផ្នែកជាមុនសម្រាប់ព្យាបាលជំងឺ ដែលស្មើនឹង 100%នៃទឹកប្រាក់ត្រូវបានធានា ប្រសិនបើធ្វើរោគវិនិច្ឆ័យលើកដំបូងរកឃើញជំងឺធ្ងន់ធ្ងរមួយ ឬច្រើនប្រភេទនៃជំងឺធ្ងន់ធ្ងរទាំង 34ប្រភេទ ដូចមានចែងក្នុង ខ និងលក្ខខណ្ឌនៃកិច្ចសន្យា (ក្រៅពីជំងឺមហារីកសុដន់ មហារីកស្បូន មហារីកមាត់ស្បូន និងមហារីកក្រពេញប្រូស្តាត) | បុព្វលាភដែលត្រូវបង់លើកក្រោយៗនឹងត្រូវបានលើកលែង ប្រសិនបើធ្វើរោគវិនិច្ឆ័យលើកដំបូងរកឃើញជំងឺធ្ងន់ធ្ងរប្រភេទ A ឬប្រភេទ B |

## អត្ថប្រយោជន៍ 6 ក្នុង គម្រោងតែ 1

| | |
|---|---|
| អត្ថប្រយោជន៍នៅរស់រានមានជីវិត | 1 |
| អត្ថប្រយោជន៍នៅពេលដល់កាលកំណត់ | 2 |
| អត្ថប្រយោជន៍សម្រាប់ជំងឺធ្ងន់ធ្ងរ | 3 |
| ការលើកលែងបុព្វលាភនៅពេលកើតជំងឺធ្ងន់ធ្ងរ | 4 |
| មរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយជំងឺ | 5 |
| មរណភាព ឬពិការភាពជាអចិន្ត្រៃយ៍ដោយគ្រោះថ្នាក់ជាយថាហេតុ | 6 |




# ការបង្ហាញអំពីអត្ថប្រយោជន៍ធានារ៉ាប់រង

## អ្នកស្រីម៉ាលី / អាយុ 25ឆ្នាំ / ទឹកប្រាក់ត្រូវបានធានា $50,000 / បុព្វលាភប្រចាំឆ្នាំ $2,450 / រយៈពេលបង់បុព្វលាភ 30ឆ្នាំ




អត្ថប្រយោជន៍ធានារ៉ាប់រងសរុបដែលអ្នកស្រីទទួលបានគឺ $266,150
(50,000 + 66,150 + 50,000 + 100,000)
បុព្វលាភដែលអ្នកស្រីបានបង់សរុបគឺ $7,350 ($2,450 x 3)




អត្ថប្រយោជន៍ធានារ៉ាប់រងសរុបដែលអ្នកស្រីទទួលបានគឺ $236,250
(50,000 + 61,250 + 75,000 + 50,000)
បុព្វលាភដែលអ្នកស្រីបានបង់សរុបគឺ $12,250 ($2,450 x 5)

## ករណីមិនធានា

១. ក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ ប្រសិនបើនៅពេលដាក់ពាក្យស្នើសុំធានារ៉ាប់រង អ្នកស្នើសុំមិនបានជូនដំណឹងពិតដល់ក្រុមហ៊ុន ហើយមានការលាក់បាំងអំពីស្ថានភាពសុខភាពដែលមានសភាពមិនល្អ ឬការងារដែលមានហានិភ័យខ្ពស់របស់អ្នកត្រូវបានធានារ៉ាប់រង ដូចករណីរៀបរាប់ខាងក្រោម៖

(១) អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺធ្ងន់ធ្ងរ ដូចបានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ៣៖ “38 ប្រភេទនៃជំងឺធ្ងន់ធ្ងរ” នៃ ខ និងលក្ខខណ្ឌធានារ៉ាប់រង

(២) អ្នកត្រូវបានធានារ៉ាប់រងបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺរ៉ាំរ៉ៃមួយ ឬច្រើនប្រភេទ ឬជំងឺស្រួចស្រាវ ឬជំងឺសតិអារម្មណ៍

(៣) អ្នកត្រូវបានធានារ៉ាប់រងទទួលរងពិការភាព ឬមុខងារភ្នែក ត្រចៀក ឬចលនារាងកាយរបស់អ្នកត្រូវបានធានារ៉ាប់រងមានសភាពមិនប្រក្រតី

(៤) អ្នកត្រូវបានធានារ៉ាប់រងប្រកបមុខរបរមានហានិភ័យខ្ពស់ដែលក្រុមហ៊ុនមិនអាចធានាបាន

(៥) អាយុពិតប្រាកដរបស់អ្នកត្រូវបានធានារ៉ាប់រងនៅពេលដែលកិច្ចសន្យាបង្កើតមិនសមស្របតាមអាយុសម្រាប់ដាក់ពាក្យស្នើសុំ ហើយអ្នកស្នើសុំធានារ៉ាប់រងមានចេតនាលាក់បាំងអំពីរឿងនេះ។

២. ក្រុមហ៊ុននឹងមិនមានទំនួលខុសត្រូវក្នុងការផ្តល់សំណងធានារ៉ាប់រងឡើយ ប្រសិនបើមានព្រឹត្តិការណ៍ស្ថិតក្រោមការធានារ៉ាប់រងកើតឡើងដោយសារតែករណីណាមួយដូចខាងក្រោម៖

(១) អ្នកស្នើសុំធានារ៉ាប់រង ឬអ្នកទទួលផលមានចេតនាធ្វើឃាត ឬបង្ករបួសទៅលើអ្នកត្រូវបានធានារ៉ាប់រង

(២) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការវាយតប់គ្នា ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ឬអ្នកត្រូវបានធានារ៉ាប់រងបង្ករបួសលើខ្លួនឯងដោយចេតនា

(៣) អ្នកត្រូវបានធានារ៉ាប់រងជាប់ពាក់ព័ន្ធនឹងការជ្រមុជទឹក ការលោតឆ័ត្រយោង ការឡើងភ្នំ ការផ្សងព្រេង ការសម្តែងបច្ចេកទេសពិសេស ការប្រណាំងរថយន្ត

(៤) អ្នកត្រូវបានធានារ៉ាប់រងបើកបរក្នុងស្ថានភាពស្រវឹង បើកបរក្នុងស្ថានភាពគ្រោះថ្នាក់ បើកបរដោយគ្មានបណ្ណបើកបរត្រឹមត្រូវ ឬបើកបរយានយន្តដោយគ្មានការចុះបញ្ជីត្រឹមត្រូវ ដែលបានកំណត់ដោយច្បាប់

(៥) អ្នកត្រូវបានធានារ៉ាប់រងទទួលរងនូវឧប្បត្តិហេតុខាងវេជ្ជសាស្រ្ត ដោយសារការវះកាត់កែសម្ផស្ស ឬការវះកាត់ផ្សេងៗ

(៦) អ្នកត្រូវបានធានារ៉ាប់រងប្រព្រឹត្តិល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយពរពោះជំនួស អ្នកដទៃ

(៧) សង្គ្រាម ការប៉ះទង្គិចផ្នែកយោធា ការបះបោរឬការបះបោរប្រដាប់អាវុធ ការផ្ទុះនុយក្លេអ៊ែរ ឬវិទ្យុសកម្មនុយក្លេអ៊ែរ ឬការចម្លងរោគពីនុយក្លេអ៊ែរ។

# ចំណាំ៖

ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នា
ដោយសង្ខេប។
សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង
រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា
និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា
សូមអាន ខ និងលក្ខខណ្ឌធានារ៉ាប់រង។


ទំនាក់ទំនងមកកាន់យើងខ្ញុំ

023-989-218 / 098-989-218

service@gc-life.com.kh www.gc-life.com.kh

វ៉ែនផាក ផ្ទះលេខ A១២ ផ្លូវR៨
ភូមិ ១ សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ